**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៦.០១៣.០១៧...៧៨១...សណ.ស.ក

*រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៧*

# សេចក្តីជូនដំណឹង

ធនាគារជាតិនៃកម្ពុជា មានសេចក្តីសោមនស្សរីករាយសូមជម្រាបសាធារណជនមេត្តាជ្រាបថា ក្នុងគោលដៅពង្រឹងកិច្ចការពារអតិថិជនដែលប្រើប្រាស់សេវាហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានបង្កើតក្រុមការងារគាំពារអតិថិជន និងបានរៀបចំក្រុមការងារទទួលការហៅទូរស័ព្ទពីសាធារណជនដែលមានចម្ងល់ ឬបញ្ហាពាក់ព័ន្ធនឹងការប្រើប្រាស់សេវាហិរញ្ញវត្ថុទាំងនេះ។

សាធារណជនអាចទូរស័ព្ទមកលេខដូចខាងក្រោម ជារៀងរាល់ថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ចាប់ពីម៉ោង ៨ព្រឹក ដល់ម៉ោង ៥ល្ងាច៖

- ខ្សែទី១ ៖ ០៨៥ ៦០០ ០០២
- ខ្សែទី២ ៖ ០៨៥ ៦០០ ០០៣
- ខ្សែទី៣ ៖ ០៩៨ ២២០ ០០១
- ខ្សែទី៤ ៖ ០៩៨ ២២០ ០០២

ក្រុមការងារគាំពារអតិថិជនរបស់ធនាគារជាតិនៃកម្ពុជា នឹងរង់ចាំទទួលការហៅទូរស័ព្ទចូលរបស់លោក-អ្នក។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

**ទំនាក់ទំនងព័ត៌មានបន្ថែម៖**

ផ្នែកទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៩០ ១៩៦
អ៊ីម៉ែល ៖ nbccommunication@nbc.org.kh